# កម្មវិធីនៃមជ្ឈមណ្ឌលខេមរសិក្សា សម្រាប់ឆ្នាំសិក្សា ២០០១-២

ដោយ *សាស្ត្រាចារ្យ ដេវីដ ឆាន់ត្លឺរ* ទីប្រឹក្សាជាន់ខ្ពស់នៃ ម.ខ.ស.

នៅពេលដែលមជ្ឈមណ្ឌលខេមរសិក្សា (ម.ខ.ស.) នៅមានការគាំទ្រពីមូលនិធិប្រាសាទបុរាណពិភពលោក និង បណ្តាសប្បុរសជនតទៅទៀត មជ្ឈមណ្ឌលក៏បានទទួលការឧបត្ថម្ភពីសំណាក់មូលនិធិ លូស មូលនិធិ រ៉ុកឺហ្វេល្ល័រ និង ឯកាធិកម្ម សេនរបេរី ដែលមានបំណងប្រគល់អាហារូបករណ៍ ។ អាហារូបករណ៍អស់នោះ នឹងបណ្តាលឲ្យ ម.ខ.ស. អភិវឌ្ឍកម្មវិធីសិក្សាមួយចំនួន ដើម្បីអាចបន្តបេសកកម្មបាន ។

ពីឆ្នាំ ២០០១ ដល់ ២០០៤ មូលនិធិ លូស មានបំណងគាំទ្រកម្មវិធីប្រចាំឆ្នាំ ប្រកបដោយអាហារូបករណ៍សម្រាប់ធ្វើការស្រាវជ្រាវ នៅប្រទេសកម្ពុជា ១ ឬ ២ ។ កម្មវិធីនេះសម្រាប់តែអ្នកស្រាវជ្រាវដែលមានសញ្ជាតិអាមេរិកាំ ។ គេនឹង ពិភាក្សាពាក្យសុំចុះឈ្មោះជាបេក្ខជនសម្រាប់ឆ្នាំទី ១ នៅខែវិច្ឆិកា ២០០១ ។ ពាក្យសុំត្រូវបានធ្វើមុនថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០១ (សូមមើលលិខិតផ្សាយជាភាសាអង់គ្លេសនៅក្នុង *សិក្សាចក្រ* លេខនេះ) ។ នៅពេលដែលយើងខ្ញុំកំពុងសរសេរអត្ថបទនេះ (ខែកក្កដា ២០០១) យើងបានទទួលពាក្យសុំបេក្ខភាព ឬ ពាក្យសុំពត៌មាន ចំនួនជាង៣០ហើយ ។ គឺគណៈកម្មាធិការ វិទ្យាសាស្ត្ររបស់ ម.ខ.ស. ដែលមានរូបខ្ញុំជាប្រធាន ដែលនឹងជ្រើសរើសបេក្ខជន ១ រូប ឬច្រើនរូប នៅខែតុលា ឬ វិច្ឆិកា ឆ្នាំ ២០០១ ខាងមុខនេះ សម្រាប់ឆ្នាំ ២០០២ ។ យើងសង្ឃឹមថាអ្នកទទួលអាហារូបករណ៍អាចចាប់ ផ្តើមធ្វើការស្រាវជ្រាវនៅប្រទេសខ្មែរ នៅដើមឆ្នាំ ២០០២ ខាងមុខនេះ។

មូលនិធិ រ៉ុកឺហ្វេល្ល័រ គាំទ្រកម្មវិធីស្រាវជ្រាវចំនួន ៣ ក្នុងរយៈពេល ៣ ឆ្នាំ ខាងមុខនេះ នៅក្នុងវិស័យការសិក្សាសម័យមុនអង្គរ វិស័យស្ថាបត្យកម្មក្នុងស្រុក និង វិស័យនរវិទ្យាទីក្រុង ។ យើងបានជ្រើសរើសវិស័យទាំង ៣ នេះ ត្បិតមានបណ្តាគណៈកម្មការវិស័យ ដែលបានប្រជុំគ្នាកាលពីសិក្ខាសាលា ដែល ម.ខ.ស. បានរៀបចំធ្វើនៅខែមករា ឆ្នាំ ២០០១ កន្លងមកនេះ ។

នាយក្រុមរបស់គម្រោងការនីមួយៗ គឺ សាស្ត្រាចារ្យ **ចន មិគ្សិច** នៃ សាកលវិទ្យាល័យជាតិសិង្ហបុរី សម្រាប់វិស័យទី ១ លោក **ហ្វ្រង់ស្វា តាំងឌុយអ៊ីយ៉េ** នៃ ម.ខ.ស. សម្រាប់វិស័យទី ២ និងបណ្ឌិត **ទិល្លេម ខុល្លិន្ស** នៃសាកលវិទ្យាល័យខាលីហ្វរនៀ (ប៊ឺរខ្លី) សម្រាប់វិស័យទី ៣ ។ នាយក្រុមនីមួយៗ នឹងធ្វើការជាមួយអ្នកស្រាវជ្រាវកម្ពុជា ដែលមានបទពិសោធន៍ ដើម្បីអភិវឌ្ឍកម្មវិធីស្រាវជ្រាវ បណ្តុះបណ្តាលអ្នកស្រាវជ្រាវកម្ពុជា ហើយនិងរៀបចំសម្ភារះ ដែលនឹងបង្ហាញនៅពេលដែល ម.ខ.ស. ធ្វើសិក្ខាសាលា និង សន្និសីទ នៅឆ្នាំ ២០០២ និង ២០០៣ ខាងមុខនេះ ។

យើងបានចាប់ធ្វើការចរចាជាមួយមូលនិធិមួយចំនួនទៀត ដែលអាចឧបត្ថម្ភ ម.ខ.ស. ក្នុងកម្មវិធីបោះពុម្ពផ្សាយ កម្មវិធីបណ្តុះបណ្តាលអ្នកស្រាវជ្រាវកម្ពុជាខាងវិធីវិទ្យាស្រាវជ្រាវ ហើយសម្រាប់ការរៀបចំឲ្យធ្វើការជ្រើស រើសនិស្សិតកម្ពុជា ដើម្បីឲ្យគេអាចបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅឯបរទេស ។ ការគាំទ្របែបនេះ ជាការចាំបាច់ បើសិនជា ម.ខ.ស. ចង់មានទម្រង់ការសិក្សា ដែលផ្តល់ផលប្រយោជន៍ដល់ខេមរវិទ្យា នៅក្នុងប្រទេសកម្ពុជា និងនៅក្នុងក្របខ័ណ្ឌអន្តរជាតិ ៕




The CKS library ~ បណ្ណាល័យមជ្ឈមណ្ឌលខេមរសិក្សា ~ La bibliothèque du CEK